# ច្បាប់

# ស្តីពី

# ហិរញ្ញវត្ថុសម្រាប់ឆ្នាំ១៩៩៤

## ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ

## ០២ នស

## ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣

# ជំពូកទី ២

## អំពីចំណូលពន្ធដារ និង ពន្ធគយ

## ពន្ធលើប្រាក់ចំណេញ

### ផ្នែកទី I

### បទបញ្ញត្តិទូទៅ

មាត្រា៨ .._ ត្រូវបានបង្កើតពន្ធប្រចាំឆ្នាំលើប្រាក់ចំណេញខាងឧស្សាហកម្ម សិប្បកម្ម ពាណិជ្ជកម្ម សេវាកម្ម ដោយរាប់បញ្ចូលទាំង អាជីវកម្មព្រៃឈើ អណ្តូងរ៉ែ និង នេសាទ ដើម្បីជាប្រយោជន៍ដល់ថវិការដ្ឋ ។

មាត្រា៩ .._ ពន្ធនេះត្រូវកំណត់លើប្រាក់ចំណេញ ដែលសំរេចបានដោយរូបវន្តបុគ្គល ឬ នីតិបុគ្គលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា១០ .._ ពន្ធនេះកំណត់ :

- នៅគ្រឹះស្ថានអាជីវកម្មជាគោលដើមបើមានគ្រឹះស្ថានមួយ ឬ ច្រើន
- នៅទីស្នាក់ការរបស់ក្រុមហ៊ុន ប៉ុន្តែអង្គការពន្ធអាចកំណត់កន្លែងយកពន្ធ នៅកន្លែងចាត់ការជាក់លាក់
- នៅទីកន្លែងដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បើអ្នកជាប់ពន្ធមានសកម្មភាពអាជីវកម្ម ឬ មានសារៈប្រយោជន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាហើយគ្មានទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា១១ .._ ការកំណត់ពន្ធលើប្រាក់ចំណេញ ត្រូវអនុវត្តតាមរបបពិតប្រាកដ ឬ តាមរបបចំរើការ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ កំណត់តាមប្រកាសអំពីរបៀបបទកំណត់ពន្ធនេះ ដោយយោលទៅមុខរបរ កំរិតផលរបរ និង ទ្រង់ទ្រាយអាជីវកម្ម ។

### ផ្នែកទី II

### ប្រាក់ចំណេញជាប់ពន្ធ និង អត្រាពន្ធ

មាត្រា១២ .._ ពន្ធនេះត្រូវគិតលើប្រាក់ចំណេញដែលគិតចេញពីលទ្ធផលនៃតុល្យការសំរេចបានក្នុងឆ្នាំកន្លងទៅ ឬ ក្នុងរយៈពេល ១២ខែ ប្រសិនបើរយៈពេលនេះពុំស្របទៅតាមឆ្នាំធម្មតា ។

បើប្រសិនជាពុំមានគុណការណាមួយ បានបញ្ឈប់ក្នុងកំឡុងនៃឆ្នាំណាមួយនោះ ពន្ធដែលត្រូវបង់សំរាប់ឆ្នាំជាបន្ទាប់ ត្រូវគិតយកយើប្រាក់ចំណេញក្នុងរយៈវេលាដែលកន្លងទៅ ចាប់តាំងពីថ្ងៃផុតរយៈពេលជាប់ពន្ធដែលកន្លងហួសទៅនោះ ។ ចំពោះសហគ្រាសថ្មី ត្រូវគិតចាប់តាំងពីថ្ងៃដែលផ្តើមធ្វើប្រតិបត្តិការ មកទល់នឹងថ្ងៃទី ៣១ ធ្នូ នៃឆ្នាំដែលត្រូវគិតពន្ធ ។

កាលបើមានធ្វើគុណការជាច្រើនគ ៗ គ្នា ក្នុងកំឡុងនៃឆ្នាំមួយដែលនោះ លទ្ធផលនៃគុណការទាំងឡាយនេះត្រូវបូករួមគ្នាធ្វើជាមូលដ្ឋាននៃពន្ធ ដែលត្រូវបង់សំរាប់ឆ្នាំតទៅ ។

មាត្រា១៣ .. ប្រាក់ចំណេញជាប់ពន្ធ គឺជាប្រាក់ចំណេញសុទ្ធបានមកពីលទ្ធផលទាំងអស់ នៃប្រតិបត្តិការគ្រប់ប្រភេទរបស់សហគ្រាសទាំងឡាយដែលសំរេចបានរួមទាំងតំលៃលើសបានមកពីការលក់ភាគនានានៃទ្រព្យសកម្មពេលកំពុងធ្វើអាជីវកម្ម ឬនៅពេលបញ្ចប់អាជីវកម្មក្តី ។

មាត្រា១៤ .. ប្រាក់ចំណេញជាប់ពន្ធបង្កើតចេញបានដោយអំពីចំនួនលើសនៃផលរបរ ដែលសំរេចបានរាស្រ័យដោយមានការចំណាយដើម្បីនាំមកវិញ និង រក្សាទុកនូវចំណេញ ។

មាត្រា១៥ .. ត្រូវបានអនុញ្ញាតអោយកាត់ចេញ ៖

១_ សោហ៊ុយទូទៅគ្រប់ប្រភេទ ចំណាយខាងបុគ្គលិក និង ឈ្នួលកម្មករ ថ្លៃឈ្នួលអចលនៈវត្ថុដែលសហគ្រាសបានជួលដើម្បីធ្វើអាជីវកម្ម

២_ រំលស់ដែលសហគ្រាសបានធ្វើដោយត្រឹមត្រូវ និង ពិតប្រាកដ

៣_ ការប្រាក់ទាំងឡាយ ដែលត្រូវបានទៅអ្នកចូលហ៊ុន ដោយគិតតែលើចំនួនប្រាក់ដែលលើសអំពីចំណែកទុនរបស់ខ្លួនប៉ុណ្ណោះ

៤_ ពន្ធទាំងឡាយដែលជាបន្ទុករបស់សហគ្រាសហើយដែលត្រូវប្រមូលក្នុងកំឡុងការិយបរិច្ឆេទ លើកលែងតែប្រាក់ពន្ធបន្ថែម និង ប្រាក់ពិន័យគ្រប់ប្រភេទ

៥_ សោហ៊ុយធ្វើដំណើរទាំងទៅទាំងមក ព្រមទាំងសោហ៊ុយស្នាក់នៅបរទេស ដែលនាយកសហគ្រាស ឬអ្នកតំណាងខ្លួនបានចំណាយ ប៉ុន្តែលុះណាតែដំណើរនោះត្រូវបានធ្វើដើម្បីជាប្រយោជន៍ដល់សហគ្រាស ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុកំណត់បញ្ជាក់អំពីរបៀបបទនៃការអនុញ្ញាតអោយកាត់ចេញខាងលើនេះ ។

មាត្រា១៦ .. ពុំត្រូវបានអនុញ្ញាតអោយកាត់ចេញ ៖

១_ ការប្រាក់នៃដើមទុនដែលជាប់ប្រើការ ( វៀរលែងតែដើមទុននេះបានមកអំពីខ្ចីគេ )

២_ ចំនួនប្រាក់ដែលទុកសំរាប់ធ្វើជាប្រាក់បំរុង ឬ សវិធានធន ។ ប៉ុន្តែសវិធានធនទាំងនេះ អាចរួចពន្ធបានកាលបើទុកសំរាប់ផ្គួសផ្គុលនូវការខាត ឬ បន្ទុកដែលមានភាពជាក់ច្បាស់ ហើយបានចុះលេខនាក្នុងការិយបរិច្ឆេទ ។

រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ កំណត់អំពីរបៀបបទអនុវត្តការកាត់ចេញនេះ ។

៣_ សោហ៊ុយចំណាយផ្ទាល់ខ្លួនរបស់អាជីវករ ។

មាត្រា១៧ .. ចំពោះក្រុមហ៊ុនដែលទទួលខុសត្រូវមានខណ្ឌសីមា ប្រាក់តំលៃការដែលបើកអោយអ្នកចូលហ៊ុនដែលជាអ្នកចាត់ការហើយដែលដាក់ចូលទៅក្នុងប្រាក់ជាសោហ៊ុយ និង ជាបន្ទុកនោះ ពុំត្រូវបានអនុញ្ញាតអោយកាត់ចេញទេ បើកាលណាភាគច្រើននៃចំណែកហ៊ុនជារបស់អ្នកចូលហ៊ុនដែលជាអ្នកចាត់ការ ។

ដើម្បីអនុវត្តនូវបទបញ្ញត្តិនេះ អ្នកចាត់ការទាំងឡាយដែលពុំមែនជាអ្នកចូលហ៊ុន ត្រូវចាត់ទុកថាជាអ្នកចូលហ៊ុនដែរ បើកាលណាសហព័ទ្ធ ឬ កូនរបស់ខ្លួនដែលពុំទាន់បានរួចពីអាណាព្យាបាល មានឋានៈជាអ្នកចូលហ៊ុន ។ ក្នុងករណីនេះក៏ដូចជាក្នុងករណីដែលអ្នកចាត់ការជាអ្នកចូលហ៊ុនដែរ ត្រូវចាត់ទុកជារបស់អ្នកចាត់ការបណ្តាភាគហ៊ុនដែលជាកម្មសិទ្ធិ ឬសិទ្ធិអាស្រ័យផលរបស់កូនមិនទាន់រួចផុតពីអាណាព្យាបាល និង សហព័ទ្ធរបស់ខ្លួន ។

មាត្រា១៨ .. ក្នុងករណីដែលមានឱនភាពក្នុងការិយបរិច្ឆេទណាមួយ ឱនភាពនោះត្រូវចាត់ទុកជាបន្ទុកសំរាប់ការិយបរិច្ឆេទបន្ទាប់ហើយត្រូវកាត់ឱនភាពនោះចេញពីប្រាក់ចំណេញសំរេចបានក្នុងការិយបរិច្ឆេទបន្ទាប់នោះ ។ បើប្រាក់ចំណេញនេះមិនគ្រប់គ្រាន់សំរាប់ទូទាត់ជាស្ថាពរទេចំណែកនៃឱនភាពដែលនៅសេសសល់ ត្រូវយោងទៅការិយបរិច្ឆេទបន្តបន្ទាប់រហូតដល់ ការិយបរិច្ឆេទទីប្រាំ គិតចាប់ពីការិយបរិច្ឆេទដែលមានឱនភាព ។

មាត្រា១៩ .. ដើម្បីគិតពន្ធលើសហគ្រាសដែលនៅក្រោមបង្គាប់ ឬ ដែលមានការត្រួតត្រានៃសហគ្រាសដែលស្ថិតនៅក្រៅប្រទេសកម្ពុជានោះ ប្រាក់ចំណេញដែលផ្ទេរដោយមិនចំពោះអោយដល់សហគ្រាសទាំងឡាយដែលនៅក្រៅប្រទេសកម្ពុជាទោះផ្ទេរដោយដំឡើងថ្លៃ ឬ បន្ថយនូវតំលៃទិញ ឬ តំលៃលក់ក្តី ទោះដោយមធ្យោបាយដទៃទៀតក្តី ត្រូវបញ្ចូលទៅក្នុងលទ្ធផលដែលគិតឃើញក្នុងបញ្ជីគណនេយ្យ ។

ត្រូវធ្វើដូចគ្នានេះដែរចំពោះសហគ្រាសទាំងឡាយ ដែលស្ថិតនៅក្រោមបង្គាប់នៃសហគ្រាសណាមួយ ឬ ក្រុមណាមួយដែលមានការត្រួតត្រាសហគ្រាសនៅក្រៅប្រទេសកម្ពុជា ។

បើពុំមានមូលដ្ឋានអ្វីច្បាស់លាស់សំរាប់ធ្វើការកែតំរូវអោយបានត្រឹមត្រូវដូចមានចែងខាងលើនេះទេ ការកំណត់ផលទាំងឡាយដែលត្រូវជាប់ពន្ធត្រូវបានធ្វើឡើងដោយប្រៀបធៀបទៅនឹងផលរបស់សហគ្រាសដែលមានស្ថានភាពអាជីវកម្មដូចគ្នាហើយដែលធ្វើអាជីវកម្មធម្មតា ។

មាត្រា២០ .. ពន្ធលើប្រាក់ចំណេញ ត្រូវបង់តាមអត្រាកំណើនតាមថ្នាក់និមួយៗលើចំនួនប្រាក់ចំណេញប្រចាំឆ្នាំ ដូចមានកំណត់ក្នុង តារាងខាងក្រោម:

| ប្រាក់ចំណេញសំរាប់គិតពន្ធប្រចាំឆ្នាំ | អត្រាពន្ធ |
|---|---|
| ដល់ ១.០០០.០០០ ៛ | ១០% |
| ពី ១.០០០.០០១ ៛ ដល់ ១០.០០០.០០០ ៛ | ១៥% |
| ពី ១០.០០០.០០១ ៛ ដល់ ២០.០០០.០០០ ៛ | ២០% |
| លើសពី ២០.០០០.០០០ ៛ | ៣០% |

## ផ្នែកទី III

## ភារកិច្ចរបស់អ្នកជាប់ពន្ធ

មាត្រា២១ .. អ្នកជាប់ពន្ធលើប្រាក់ចំណេញ ដែលត្រូវបង់ពន្ធតាមរបបពិតប្រាកដនោះ ត្រូវផ្ញើជូនជារៀងរាល់ឆ្នាំទៅ អគ្គការពន្ធនូវលិខិតប្រកាសអំពីប្រាក់ចំណេញដែលខ្លួនបានសំរេចក្នុងឆ្នាំមុន ឬ ក្នុងការិយបរិច្ឆេទដែលគិតបញ្ចីក្រោយបង្អស់ ។ លិខិតប្រកាសនោះ ត្រូវចុះបញ្ជីជាយាងយូរបំផុតក្នុងរយៈវេលា ៣ខែ ក្រោយពីផុតកាលឆ្នាំ ឬពីពេលបិទការិយបរិច្ឆេទដែលគិតបញ្ជីក្រោយបង្អស់នោះ ហើយត្រូវមានភ្ជាប់មកជាមួយនូវឯកសារដូចតទៅ ៖

១_ តុល្យការ

២_ គណនីលទ្ធផល

៣_ តារាងស្តីពីពត៌មានបន្ថែម

ចំពោះសហគ្រាសដែលមានឱនភាព ក៏ត្រូវធ្វើលិខិតប្រកាសអំពីចំនួនខាតនោះតាមបែបបទ និង ក្នុងរយៈវេលាដូចគ្នា ។

មាត្រា២២ ._ អ្នកជាប់ពន្ធលើប្រាក់ចំណេញ ត្រូវបង់រំដោះនូវពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំលើមូលដ្ឋាន ០.៥% (សូន្យក្បៀសប្រាំភាគរយ) សរុបផលរបរដែលសហគ្រាសរបស់ខ្លួនទាំងអស់សំរេចបាន ក្នុងពេលជាមួយគ្នា និង ក្នុងលក្ខណៈដូចគ្នានឹងការបង់អាករលើផលរបរជូនទៅអង្គការពន្ធ

ក្នុងករណីដែលសហគ្រាសត្រូវបានលក់ ប្រាក់រំដោះដែលបានបង់រួចមកហើយ ត្រូវកាត់បញ្ចូលក្នុងគណនីនៃអ្នកទិញដែលជាអ្នកទទួលខុសត្រូវទាំងស្រុងនូវប្រាក់ពន្ធចាប់ពីថ្ងៃលក់សហគ្រាសនោះ ។

នៅពេលគិតពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ អង្គការពន្ធត្រូវផាត់ចេញពីចំនួនប្រាក់ពន្ធត្រូវបង់ នូវសរុបប្រាក់រំដោះដែលបានបង់រួចនោះ ហើយផ្តល់បំពេញជាលាយលក្ខណ៍អក្សរជូនអ្នកជាប់ពន្ធអោយចង់បង្គប់ ដើម្បីធ្វើការទូទាត់ជាស្ថាពរ

បើសរុបទឹកប្រាក់រំដោះមានចំនួនច្រើនជាងប្រាក់ពន្ធត្រូវបង់ ចំនួនទឹកប្រាក់លំអៀងនេះចាត់ទុកជាប្រាក់រំដោះសំរាប់ឆ្នាំក្រោយ ឬ បង្វិលសងវិញក្នុងករណីដែលសហគ្រាសត្រូវបានបញ្ឈប់ ។

មាត្រា២៣ ._ អ្នកជាប់ពន្ធតាមរបបម៉ៅការត្រូវធ្វើលិខិតប្រកាសជូនអង្គការពន្ធក្នុងមូលដ្ឋានដែលខ្លួនមានសកម្មភាពអាជីវកម្មជារៀងរាល់មុនដំណាច់ឆ្នាំដែលកំពុងប្រកបកិច្ចការយ៉ាងយឺតបំផុតនៅថ្ងៃ ៣១ ខែ តុលា តាមគំរូដែលអង្គការពន្ធបានផ្តល់ជូន ចំនួនប្រាក់ចំណេញម៉ៅការត្រូវកំណត់ដោយអង្គការពន្ធបន្ទាប់ពីបានត្រួតពិនិត្យ និង ពិភាក្សាជាមួយអាជីវករ ឬក្រុមហ៊ុន ប្រាក់ចំណេញម៉ៅការនេះ ត្រូវគិតតាមអត្រាចំណេញ ដោយយោលតាមប្រភេទ និង តាមមុខរបរអាជីវកម្មដែល មិនមានកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ការិតពន្ធនេះត្រូវកំណត់ជាស្ថាវរន្តសំរាប់រយៈពេលមួយមានកំណត់ ៣ ខែ, ៦ ខែ, ១ ឆ្នាំ ។

អ្នកជាប់ពន្ធលើប្រាក់ចំណេញតាមរបបម៉ៅការ ត្រូវបង់ពន្ធនេះប្រចាំខែជារៀងរាល់ខែ តាមពេលកំណត់ដោយអង្គការពន្ធ ។

## ផ្នែកទី IV

## សិទ្ធិទាក់ទងពត៌មាន

មាត្រា២៤ ._ អង្គការពន្ធដែលមានសមត្ថកិច្ច ត្រូវត្រួតពិនិត្យមើលនូវរាល់លិខិតប្រកាស មានសិទ្ធិអាចសួររកនូវសេចក្តីបំភ្លឺ និង សេចក្តីបញ្ជាក់ អំពីអ្នកជាប់ពន្ធ មានសិទ្ធិកែតំរូវលិខិតប្រកាស ប៉ុន្តែត្រូវអោយដំណឹងដល់សាមីខ្លួនអ្នកជាប់ពន្ធជាមុន អំពីមូលដ្ឋានដែលខ្លួនចំរុង និងចាត់ទុកជាគោល សំរាប់គិតយកពន្ធ ហើយត្រូវប្រាប់សាមីខ្លួនអ្នកជាប់ពន្ធទាំងនេះអោយទទួលយល់ព្រម ឬ អោយធ្វើជូនមកនូវសេចក្តីយល់ព្រមទទួល ឬ នូវយោបល់របស់គេក្នុងរយៈពេល ១ ខែ ។

បើពុំមានចំលើយក្នុងរយៈវេលានេះទេ អង្គការពន្ធត្រូវកំណត់នូវគោលសំរាប់គិតយកពន្ធ ។ សាមីខ្លួនមានសិទ្ធិតវ៉ាបាននៅវេលាក្រោយដែលធ្វើបញ្ជីរួចហើយ ប៉ុន្តែត្រូវជូនភស្តុតាងពិតប្រាកដដែលខ្លួនលើកមកអះអាងនោះ ។

បើសាមីខ្លួនបានផ្ញើយោបល់មកក្នុងរយៈពេល ១ខែ ដូចពោលខាងលើនេះហើយអង្គការពន្ធនៅតែប្រកាន់សេចក្តីដែលខ្លួនបានកែតំរូវនោះ អង្គការពន្ធអាចដាក់ពន្ធបាន ប៉ុន្តែសាមីអ្នកជាប់ពន្ធ មានសិទ្ធិតវ៉ាក្រោយពេលដែលធ្វើបញ្ជីពន្ធរួច ។ អង្គការពន្ធត្រូវបង្ហាញនូវភស្តុតាងដែលជាមូលដ្ឋាននៃការកែតំរូវនោះដល់អ្នកជាប់ពន្ធ ។

## ពន្ធលើឈ្នួលផ្ទះ និង ដី

### ផ្នែកទី I

### បទបញ្ញត្តិទូទៅ

*មាត្រា២៥* ._ ត្រូវបានបង្កើតពន្ធលើប្រាក់ឈ្នួលផ្ទះ និង ដី ដើម្បីជាប្រយោជន៍ដល់ថវិការដ្ឋ ។

*មាត្រា២៦* ._ ពន្ធលើប្រាក់ឈ្នួលផ្ទះ និង ដី ត្រូវកំណត់យកលើប្រាក់ឈ្នួលដែលបានមកពីការជួល ៖

- អាគារដែលសង់លើដី ដូចជា : ផ្ទះ រោងចក្រ ភោជនីយដ្ឋាន ការិយាល័យ ។ ល ។
- ហត្ថឧបករណ៍ដែលជាប់ជាមួយគ្រឹះស្ថានឧស្សាហកម្ម
- ឋានភណ្ឌពាណិជ្ជកម្ម ឧស្សាហកម្ម ដែលនៅនឹងមួយកន្លែង អាគារធំៗដែលទុកដាក់ចាតុរាវ ឬ ផលិតផលផ្សេងៗ ដូចជាប្រេងឥន្ធនៈ កៅស៊ូចាក់ថ្នាំ គ្រាប់ធញ្ញជាតិ
- ផ្ទះអណ្តែតទឹក កញ្ចាល់សំរាប់ធ្វើជាលំនៅដ្ឋាន ឬ ដើម្បីប្រកបអាជីវកម្មផ្សេងៗ
- ដីធ្លី ដែលគ្មានសំណង់ ដោយរាប់បញ្ចូលទាំងកន្លែងយកថ្ម យករ៉ែ ឡូតិ៍ ប៊ឹងបួរ ស្រែអំបិល ។

*មាត្រា២៧* ._ ពន្ធលើប្រាក់ឈ្នួលផ្ទះ និង ដីនេះមិនត្រូវអនុវត្តលើ ៖

- ប្រាក់ឈ្នួលផ្ទះ និង ដី ដែលបានគិតបញ្ចូលក្នុងប្រាក់ចំណេញ នៃសហគ្រាស ឧស្សាហកម្ម សិប្បកម្ម កសិកម្ម ពាណិជ្ជកម្ម ឬ មុខរបរអាណិជ្ជកម្មណាមួយ ដែលស្ថិតក្នុងក្របខ័ណ្ឌត្រូវយកពន្ធលើប្រាក់ចំណេញតាមរបបពិតប្រាកដ ។
- ប្រាក់ដែលអ្នកជួលបានតំកល់ទុកធ្វើប្រាក់ធានា ហើយនៅពេលចប់កិច្ចសន្យា កម្មសិទ្ធិករត្រូវប្រគល់គ្រប់ចំនួនអោយអ្នកជួលវិញ ។

*មាត្រា២៨* ._ ពន្ធនេះត្រូវប្រមូលពីកម្មសិទ្ធិករ ឬ សិទ្ធិវន្តរបស់កម្មសិទ្ធិករ ។

*មាត្រា២៩* ._ អត្រាពន្ធលើឈ្នួលផ្ទះ និង ដី ត្រូវបានកំណត់ស្មើនឹង ១០ ភាគរយ នៃប្រាក់ឈ្នួលសុទ្ធ ។ ប្រាក់ឈ្នួលសុទ្ធ គឺជាប្រាក់ឈ្នួលដែលបានចុះកិច្ចសន្យា ឬ បានព្រមព្រៀងជាមួយអ្នកជួល ។

មាត្រា៣០ .- ត្រូវបានលើកលែងមិនប្រមូលពន្ធចំពោះប្រាក់ឈ្នួលផ្ទះ និង ដី ដែលមានកំរិតទាប ។
រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសមត្ថកិច្ចកំណត់អំពីការលើកលែងនេះ ។

មាត្រា៣១ .- ពន្ធលើប្រាក់ឈ្នួលផ្ទះ និងដីត្រូវបង់ប្រចាំខែជារៀងរាល់ខែ គិតចាប់ពីថ្ងៃដែលបានចុះកិច្ចសន្យា ឬបានព្រមព្រៀងគ្នា ។

## ផ្នែកទី II

## ភារកិច្ចរបស់កម្មសិទ្ធិករ និង អ្នកជួល

មាត្រា៣២ .- កម្មសិទ្ធិករមានភារកិច្ចដូចតទៅ ៖

ក- ត្រូវប្រកាសក្នុងរយៈពេល១៥ថ្ងៃ គិតពីថ្ងៃចុះកិច្ចសន្យាជួល ឬ ចាប់ពីថ្ងៃមានការប្រែប្រួលអំពីកិច្ចសន្យា ជូនទៅអង្គការពន្ធនៅក្នុងមូលដ្ឋាន ដែលកម្មវត្ថុនៃកិច្ចសន្យានោះតាំងនៅតាមគំរូដែលអង្គការពន្ធផ្តល់អោយ និង ត្រូវជូនភ្ជាប់មកជាមួយនូវច្បាប់ថតចំលងនៃកិច្ចសន្យាជួលចំនួនមួយច្បាប់ ។

ខ- ពេលឈប់ជួលក្នុងរវាង១៥ថ្ងៃ ត្រូវប្រកាសជាលាយលក្ខណ៍អក្សរ ជូនទៅអង្គការពន្ធដែលបានទទួលប្រកាសពីមុន ពាក្យប្រកាសទាំងឡាយត្រូវមានចុះកាលបរិច្ឆេទ និង ហត្ថលេខាដោយត្រឹមត្រូវរបស់កម្មសិទ្ធិករ ឬ អ្នកទទួលអាណត្តិដោយបានអនុញ្ញាត្តិ ។

គ- ផ្តល់បង្កាន់ដៃទទួលប្រាក់ឈ្នួលជូនអ្នកជួលក្នុងពេលទទួលប្រាក់ឈ្នួលម្តង ៗ ។

ឃ- ក្នុងរយៈពេលកំណត់ត្រូវបង់អោយគ្រប់ចំនួននូវប្រាក់ពន្ធ ឬ ប្រាក់ពិន័យ ដែលអង្គការពន្ធបានកំណត់ ។

មាត្រា៣៣ .- ក- ក្នុងករណីដែលកម្មសិទ្ធិករ មិនព្រមបង់ពន្ធលើឈ្នួលផ្ទះ ឬ ដីនោះ អ្នកជួលមានភារកិច្ចទទួលខុសត្រូវ ដកប្រាក់ថ្លៃឈ្នួលដើម្បីបង់ពន្ធអោយគ្រប់ចំនួន ។

ខ- អ្នកជួលផ្ទះ ឬ ដី ត្រូវបង្ហាញបង្កាន់ដៃទទួលប្រាក់ដែលកម្មសិទ្ធិករផ្តល់ជូន និង ត្រូវផ្តល់ព័ត៌មានផ្សេងៗទៀតដែលទាក់ទងអំពីការជួលចំពោះភ្នាក់ងារពន្ធដែលមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យ ។

# *អាករលើផលរបរ*

## ផ្នែកទី I

## បទបញ្ញត្តិទូទៅ

មាត្រា៣៤ .- ត្រូវបានបង្កើតអាករលើផលរបរ ដើម្បីជាប្រយោជន៍របស់ថវិការដ្ឋ ។

មាត្រា៣៥ .- បុគ្គលណាដែលប្រកបរបរទិញសំរាប់លក់វិញមួយរយៈមួយគ្រា ឬ ជានិច្ចកាល ឬ ប្រកបវិជ្ជាជីវៈខាងពាណិជ្ជកម្ម

ឧស្សាហកម្ម សិប្បកម្ម សេវាកម្ម ដោយរាប់បញ្ចូលទាំងអាជីវកម្មព្រៃឈើ អណ្តូងរ៉ែ និង នេសាទ នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា របរនៃបុគ្គលនោះត្រូវជាប់អាករលើផលរបរ ។

កិច្ចប្រតិបត្តិការទាំងឡាយដែលសមូហភាព ឬ អង្គការណាមួយធ្វើខ្លួនឯង ឬ ប្រគល់សម្បទានអោយគេធ្វើផ្លូវក្នុងមុខរបរដែលមានចែងខាងលើ ក៏ត្រូវជាប់អាករលើផលរបរនេះផងដែរ ។

មាត្រា៣៦ ._ អាករលើផលរបរត្រូវប្រមូល ៖

១_ នៅទីតាំងនៃគ្រឹះស្ថាននិមួយៗបើអ្នកជាប់អាករមានគ្រឹះស្ថានមួយ ឬ ក៏ច្រើន ។

២_ នៅទីលំនៅ ឬ ទីសំចតនៃអ្នកតំណាងដោយត្រឹមត្រូវ ដូចមានចែងក្នុងមាត្រា ៥២ បើអ្នកជាប់អាករគ្មានគ្រឹះស្ថានក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៣៧ ._ របរផ្សេងក្រៅពីការលក់ដូរត្រូវកំណត់អាករនៅកន្លែងដែលអោយខ្ចី ឬ អោយជួលកិច្ចការដែលបានធ្វើ ឬ សេវាដែលបានផ្តល់ ទោះបីវត្ថុដែលអោយខ្ចី ឬ អោយជួលកិច្ចការដែលបានធ្វើ ឬ សេវាដែលបានផ្តល់នោះនៅទីណាក៏ដោយ ។

មាត្រា៣៨ ._ ការកំណត់អាករលើផលរបរនេះ ត្រូវអនុវត្តតាមរបបពិតប្រាកដ និង តាមវិធីម៉ៅការ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ កំណត់តាមប្រកាសអំពីរបៀបបទកំណត់អាករនេះ ដោយយោលតាមមុខរបរកិតផលរបរ និង ទ្រង់ទ្រាយអាជីវកម្ម ។

មាត្រា៣៩ ._ ត្រូវបានលើកលែងអាករលើផលរបរចំពោះ ៖

១_ ការលក់ដូរផលិតផលកសិកម្មរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលផលិតបានដោយខ្លួនឯង ទោះបីផលិតផលនោះមិនទាន់កែច្នៃ ឬ ក៏កែច្នៃហើយ តាមទំលាប់នៃការងារកសិកម្ម ។

២_ ការលក់ដូរទំនិញនាំចូល ដែលអ្នកនាំចូលលក់ទំនិញនោះផ្ទាល់ខ្លួននៅក្នុងប្រទេស ឬ ចេញទៅក្រៅប្រទេស ក្នុងករណីដែលទំនិញនាំចូលទាំងនោះបានបង់អាករប្រើប្រាស់ដូចបានចែងក្នុងផ្នែកទី III ខាងក្រោម ។

៣_ អាជីវកម្មដ្ឋានចល័ត និង អចល័តតូចតាចដែលនឹងកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា៤០ ._ ការលើកលែងអាករដែលមានចែងក្នុងចំណុច១នៃមាត្រា ៣៩ មិនត្រូវអនុវត្តចំពោះការលក់ដូរផលិតផលកសិកម្មផ្សេងៗដែលបានយកមកកែច្នៃរក្សាទុកសំរាប់លក់ និង ការរៀបចំតាមរបៀបផ្សេងទៀត អាស្រ័យដោយប្រើប្រាស់ឧបករណ៍ឧស្សាហកម្ម ឬតាមវិធីពាណិជ្ជកម្មណាមួយនោះដែលពុំអាចចាត់ទុកថាជាផលិតផលបន្ទាប់បន្សំ ឬជាការបន្តបន្ទាប់នៃការងារកសិកម្មឡើយ ។

## ផ្នែកទី II

## អំពីមូលដ្ឋានគិតអាករ និង អត្រាអាករ

មាត្រា៤១ ._ អាករនេះ ត្រូវកំណត់លើចំនួនប្រាក់ដែលលក់បាន ដោយគិតទាំងសោហ៊ុយ និង ពន្ធដារផង ឬ មួយគិតតាមតំលៃវត្ថុដែលបានទទួលមកជាថ្នូរ ទាក់ទងទៅនឹង ៖

១_ បុគ្គលទាំងឡាយដែលលក់ ឬដោះដូរទំនិញសំភារៈ វត្ថុ ហើយបើនិយាយជាទូទៅគឺ សង្ហារិមវត្ថុ ឬអសង្ហារិមវត្ថុទាំងឡាយ ។

២_ បុគ្គលទាំងឡាយដែលប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា សំរាប់បរាជ័ន្ទ(?)ដែលគ្មានគ្រឹះស្ថានតាំងនៅក្នុងប្រទេសកម្ពុជា ។

៣_ អ្នកទទួលកម្រៃជើងសារ អ្នកតំណាង អ្នកទទួលអាណត្តិ ឬ អ្នកកណ្តាលទាំងឡាយដែលមានលក្ខណៈមិនទទួលត្រឹមតែកម្រៃជើងសារប៉ុណ្ណោះ គឺកម្រៃជើងសារដែលមានកំណត់ទុកជាមុនតាមតំលៃ ឬបរិមាណនៃទំនិញហើយបញ្ចូលគុណប្រយោជន៍ផ្សេងពីកម្រៃជើងសារនោះថែមទៀត ឬ មិនរាយការណ៍ជាលាយលក្ខណ៍អក្សរប្រាប់អ្នកដែលប្រគល់ការអោយខ្លួនអំពីតំលៃដែលបានព្រមព្រៀងនឹងភាគីម្ខាងទៀត ។

មាត្រា៤២ ._ សំរាប់បុគ្គលដែលប្រព្រឹត្តកិច្ចការជាអ្នកទទួលកម្រៃជើងសារ អ្នកតំណាង អ្នកទទួលអាណត្តិ អ្នកកណ្តាល ផាងម៉ៅ មុខការ អ្នកជួលវត្ថុ ឬ សេវាកម្ម ធនាគារិក អចលហារី អ្នកប្តូរប្រាក់ អាករលើផលរបរត្រូវគិតលើប្រាក់កម្រៃ ប្រាក់លោះថ្លៃ ប្រាក់ថ្លៃឈ្នួល ចុងការ និង គុណប្រយោជន៍ផ្សេងៗទៀត ។

មាត្រា៤៣ ._ សំរាប់សហគ្រាសម៉ៅការ អាករលើផលរបរត្រូវគិតយកលើតំលៃការដែលបញ្ចប់បាន ឬ ទឹកប្រាក់ក្នុងសារណា ឬ ទឹកប្រាក់ក្នុងវិក្កយប័ត្រ រួមបញ្ចូលទាំងសោហ៊ុយ និង អាករជួបមុខផង ។

មាត្រា៤៤ ._ អត្រាអាករលើផលរបរត្រូវកំណត់ ១% " មួយភាគរយ " ចំពោះកិច្ចការខាងឧស្សាហកម្ម សិប្បកម្ម និង អណ្តូងរ៉ែ ។ ក្រៅពីនេះ ត្រូវកំណត់ ២% " ពីរភាគរយ " វៀរលែងតែករណីមានចែងក្នុង មាត្រា ៤៥ និង ៤៦ នៃច្បាប់ហិរញ្ញវត្ថុនេះ ។

មាត្រា៤៥ ._ អាករលើផលរបរត្រូវឡើងដល់ ១០% ចំពោះ ៖

១_ ផលរបរផ្សេងៗទៀតរបស់សណ្ឋាគារក្រៅពីឈ្នួលបន្ទប់

២_ ផលរបរនៃអាជីវកម្ម ម៉ាស្សា និង រង្គសាល

៣_ ផលរបររបស់ភោជនីយដ្ឋាន ភេសជ្ជៈដ្ឋាន និង សប្បាយដ្ឋាន ដែលមានប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទុកជាគ្រឹះស្ថានធំតាមសេចក្តីស្នើនៃគណៈកម្មការដែលតាំងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ផ្នែកទី III

## កិច្ចការនាំទំនិញចូល

មាត្រា៤៦ ._ កិច្ចការនាំទំនិញចូល ត្រូវបង់អាករលើផលរបរហៅថា អាករប្រើប្រាស់តាមអត្រា ៤% " បួនភាគរយ " លើថ្លៃ ក្រៅគយ ។

មាត្រា៤៧ ._ អាករប្រើប្រាស់ត្រូវប្រមូលក្នុងពេលដំណាលគ្នានឹងការប្រមូលពន្ធលើទំនិញនាំចូល និង ត្រូវប្រមូលដោយអង្គការគយ ។

មាត្រា៤៨ ._ ការពិន័យជាប្រាក់ និង ពិន័យរដ្ឋបាល ទាក់ទងនឹងពន្ធលើការប្រើប្រាស់ ក៏ ស្ថិតនៅក្រោមអាណាពលនៃច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ នាំចូលដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩ ។

## ផ្នែកទី IV

## ភារកិច្ចរបស់អ្នកជាប់អាករ

មាត្រា៤៩ : អ្នកជាប់អាករលើផលរបរមានភារកិច្ចដូចតទៅ ៖

ក_ ត្រូវប្រកាសក្នុងរយៈពេល១៥ថ្ងៃ គិតពីថ្ងៃចាប់ផ្ដើមប្រកបអាជីវកម្ម ឬ ចាប់ពីថ្ងៃមានការប្រែប្រួលអំពីស្ថានភាពអាជីវក ជូនទៅអង្គភាពពន្ធនៅក្នុងមូលដ្ឋាន ដែលគ្រឹះស្ថានរបស់ខ្លួនតាំងនៅ តាមគំរូដែលអង្គភាពពន្ធផ្ដល់អោយ ។

ខ_ ពេលឈប់ប្រកបអាជីវកម្មរបស់ខ្លួន ឬ ផ្ទេរអាជីវកម្មរបស់ខ្លួនអោយអ្នកដទៃ ព្រមទាំងអ្នកទទួលផ្ទេរនោះផងត្រូវប្រកា ក្នុងរវាង ១៥ថ្ងៃ ជូនទៅអង្គភាពពន្ធដែលបានទទួលពាក្យប្រកាសពីមុន ។

គ_ ត្រូវកាន់ និង ថែរក្សាបញ្ជីគណនេយ្យ សក្ខីប័ត្រ អោយបានត្រឹមត្រូវតាមរបបគណនេយ្យដែលរដ្ឋបានកំណត់ និង តាមការណែនាំរបស់អង្គភាពពន្ធ ហើយត្រូវបង្ហាញបញ្ជីគណនេយ្យ និងសក្ខីប័ត្រទាំងនោះដល់អង្គភាពពន្ធក្នុងពេលចាំបាច់ ។

ឃ_ ត្រូវដាក់អោយស្ថិតក្រោមការត្រួតពិនិត្យរបស់អង្គភាពពន្ធចំពោះទំនិញដែលស្ថិតក្នុងអាគារលក់ដូរ ឬ ឃ្លាំង ។

មាត្រា៥០ ._ ចំពោះអ្នកជាប់អាករតាមរបបពិតប្រាកដ នៅមុនថ្ងៃទី១០រាល់ខែ ត្រូវធ្វើជូនទៅអង្គភាពពន្ធនូវលិខិតប្រកាសផលរបរនៃអាជីវកម្មរបស់ខ្លួនក្នុងខែមុនហើយត្រូវបង់អាករទៅតាមចំនួនផលរបរដែលបានប្រកាសនោះ ។ លិខិតប្រកាសនេះត្រូវមានចុះកាលបរិច្ឆេទ និង ហត្ថលេខានៃអ្នកជាប់អាករ ឬ អ្នកទទួលអាណត្តិដោយបានអនុញ្ញាត ។

បើក្នុងខែណាមួយ ពុំបានប្រកបកិច្ចការជាប់អាករអ្វីមួយទេ ក៏ត្រូវធ្វើលិខិតប្រកាសថា " គ្មាន " ជូនទៅដែរ ។

បើអ្នកជាប់អាករមានគ្រឹះស្ថានច្រើនកន្លែង ត្រូវធ្វើលិខិតប្រកាសផលរបរនោះមួយច្បាប់សំរាប់គ្រឹះស្ថាននីមួយៗ ។

មាត្រា៥១ ._ ចំពោះអ្នកជាប់អាករតាមរបបម៉ៅការត្រូវធ្វើលិខិតប្រកាសជូនអង្គភាពពន្ធក្នុងមូលដ្ឋានដែលខ្លួនមានសកម្មភាពអាជីវកម្មជា រៀងរាល់ឆ្នាំមុនពេលដាច់ឆ្នាំដែលកំពុងប្រកបកិច្ចការយ៉ាងយឺតបំផុតនៅថ្ងៃ ៣១ ខែតុលា តាមគំរូដែលអង្គភាពពន្ធបានផ្ដល់ជូន ។

ប្រាក់អាករដែលត្រូវបង់ ត្រូវផ្អែកជាមូលដ្ឋានលើផលរបរប្រចាំខែកំណត់ដោយអង្គភាពពន្ធបន្ទាប់ពីបានត្រួតពិនិត្យ និង ពិភាក្សាជាមួយអាជីវករ ឬ អ្នកតំណាង ។

កំរិតអាករនេះត្រូវកំណត់ជាស្ថេរវន្ត សំរាប់រយៈពេលមួយមានកំណត់ ៣ខែ, ៦ខែ, ១ឆ្នាំ ។

អ្នកជាប់អាករតាមរបបម៉ៅការ ត្រូវបង់អាករនេះប្រចាំខែជារៀងរាល់ខែតាមពេលកំណត់ដោយអង្គភាពពន្ធ ។

មាត្រា៥២ ._ ផ្ទះជំនួញណាដែលតាំងនៅក្រៅប្រទេសកម្ពុជា បើប្រកបអាជីវកម្មក្នុងប្រទេសកម្ពុជាត្រូវជូនឈ្មោះអ្នកតំណាងម្នាក់ដែលមានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជាទៅអង្គភាពពន្ធអោយទទួលស្គាល់ផង ។ អ្នកតំណាងនេះត្រូវទទួលខ្លួនប្រតិបត្តិតាមបែបបទដែលអ្នកជាប់អាករលើផលរបរទាំងឡាយត្រូវធ្វើ ហើយត្រូវសន្យាបង់អាករលើផលរបរជួសផ្ទះជំនួញនោះ ។

## ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ

*មាត្រា ៥៣.–*

មាត្រា ២ នៃច្បាប់ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ដែលប្រកាសឱ្យប្រើ ដោយក្រឹត្យ លេខ ២៤ ក្រ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩១ ត្រូវបានកែប្រែដូចខាងក្រោម

មាត្រា ២ ថ្មី

ពន្ធខាងលើនេះត្រូវអនុវត្តទៅលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទតាមការកំណត់ដូចខាងក្រោម :

| ប្រភេទមធ្យោបាយដឹកជញ្ជូន និង យានជំនិះ | កំរិតប្រាក់ពន្ធសំរាប់១ឆ្នាំក្នុងមួយគ្រឿង | |
|---|---|---|
| - រថយន្តដឹកទំនិញ ធុនធ្ងន់ | ១៥០ ០០០ | |
| - រថយន្តដឹកទំនិញ ធុនស្រាល | ៧៥ ០០០ | |
| - រថយន្តដឹកអ្នកដំណើរឆ្លងកាត់ខេត្ត ក្រុង ធុនធំ មានលើសពី ៣០ កៅអី | ១២០ ០០០ | |
| - រថយន្តដឹកអ្នកដំណើរឆ្លងកាត់ខេត្ត ក្រុង ធុនមធ្យម មាន ៣០ កៅអីចុះ | ៩០ ០០០ | |
| - រថយន្តដឹកអ្នកដំណើរក្នុងក្រុង ធុនធំ មានលើសពី ៣០ កៅអី | ៩០ ០០០ | |
| - រថយន្តដឹកអ្នកដំណើរក្នុងក្រុង ធុនមធ្យម មាន ៣០ កៅអីចុះ | ៦០ ០០០ | |
| - រថយន្តទេសចរណ៍ គ្រប់ប្រភេទ | គិតពីឆ្នាំផលិត | |
| | ដល់ ៥ ឆ្នាំ | លើសពី ៥ឆ្នាំ |
| - កម្លាំងដល់ ៩ សេស | ៥០ ០០០ | ៣៧ ៥០០ |
| - កម្លាំងលើសពី ៩ សេស ដល់ ១៦ សេស | ៧៥ ០០០ | ៥០ ០០០ |
| - កម្លាំងលើសពី ១២ សេស ឡើងទៅ | ១២៥ ០០០ | ៨៧ ៥០០ |
| - ត្រាក់ទ័រកំលាំង ៨២ សេស | ១៥ ០០០ | |
| - ត្រាក់ទ័រកំលាំង ៦៥ សេស | ៩ ០០០ | |
| - ត្រាក់ទ័រកំលាំង ៣៥ សេស | ៣ ០០០ | |
| - ទោចក្រយានយន្តទំហំពីស្តុង ៧០ ស.ម³ ចុះ | ៣ ០០០ | |
| - ទោចក្រយានយន្តទំហំពីស្តុងពី ៧០ ស.ម³ ទៅ ១២០ ស.ម³... | ៤ ៥០០ | |
| - ទោចក្រយានយន្តទំហំពីស្តុងចាប់ពី ១២៥ ស.ម³ ឡើងទៅ ... | ៧ ៥០០ | |
| - ត្រីចក្រយានយន្តដឹកទំនិញ ឬ អ្នកដំណើរ | ១៥ ០០០ | |

| | |
|---|---|
| <u>ចល័យាន ឬ ចល័យានយន្ត ផ្លូវទន្លេ :</u> | |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយលើសពី ៣០ ម៉ែត្រ | ១៥០ ០០០ |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយលើសពី ២០ ម៉ែត្រ ដល់ ៣០ ម៉ែត្រ | ១០០ ០០០ |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយ ២០ ម៉ែត្រ ចុះ | ៥០ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងពី ៣០ សេស ដល់ ៥០ សេស | ៨ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងពី ៥០ សេស ដល់ ១០០ សេស | ១៥ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងពី ១០០ សេស ដល់ ១៥០ សេស | ២៥ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងពី ១៥០ សេស ដល់ ២០០ សេស | ៣០ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងពី ២០០ សេស ដល់ ២៥០ សេស | ៨០ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ២៥០ សេស | ១៥០ ០០០ |
| - កាណូតនេសាទមានកំលាំងពី ១០ សេស ទៅ ៥០ សេស | ៣ ០០០ |
| - កាណូតនេសាទមានកំលាំងពី ៥០ សេស ទៅ ១០០ សេស | ៨ ០០០ |
| - កាណូតនេសាទមានកំលាំងពី ១០០ សេស ទៅ ១៥០ សេស | ១៥ ០០០ |
| - ទូកម៉ាស៊ីនចំហៀង "ជើងបង្កង" | ៥ ០០០ |
| - អូប៊រ | ២៥០ ០០០ |
| <u>ចល័យាន ឬ ចល័យានយន្ត ផ្លូវសមុទ្រ :</u> | |
| - កប៉ាល់ដឹកទំនិញដែលផ្ទុកបានត្រឹម ១ ០០០ តោនត្រូវគិតដូចផ្នែកទឹកសាប | |
| - កប៉ាល់ដឹកទំនិញផ្ទុកបានលើសពី ១ ០០០ តោន ដល់ ២ ០០០ តោន | ៧៥០ ០០០ |
| - កប៉ាល់ដឹកទំនិញផ្ទុកបានលើសពី ២ ០០០ តោន | ១ ២០០ ០០០ |
| - កប៉ាល់នេសាទដែលមានកំលាំងត្រឹម ១៥០ សេសត្រូវគិតដូចខាងផ្នែកទឹកសាប | |
| - កប៉ាល់នេសាទមានកំលាំងលើសពី ១៥០ ដល់ ២៥០ សេស | ១៥០ ០០០ |
| - កប៉ាល់នេសាទមានកំលាំងលើសពី ២៥០ ដល់ ៤០០ សេស | ៣០០ ០០០ |
| - កប៉ាល់នេសាទមានកំលាំងលើសពី ៤០០ សេស ឡើងទៅ | ៦០០ ០០០ |
| - កប៉ាល់សណ្តោងដែលមានកំលាំងត្រឹម ២៥០ សេសត្រូវគិតដូចខាងផ្នែកទឹកសាប | |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ២៥០ សេស ដល់ ៤០០ សេស | ១៥០ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ៤០០ សេស ឡើងទៅ | ៣០០ ០០០ |

## ជំពូកទី ៣

## បទបញ្ញត្តិរួមអំពីពន្ធ និង អាករ

*មាត្រា៥៤* ._ ការទទួលសិទ្ធិអោយសំរេច នូវលក្ខណៈបញ្ញត្តិនៃច្បាប់នេះ និង ការពិនិត្យកត់ត្រានូវបទល្មើសទាំងឡាយ គឺជាសមត្ថកិច្ចរបស់អង្គការពន្ធ ។

*មាត្រា៥៥* ._ ទោះក្នុងករណីណាក៏ដោយ ក្រុមរាជការទាំងឡាយព្រមទាំងសហគ្រាសដែលរដ្ឋបានអោយសម្បទាន ឬ ដែលរដ្ឋត្រួតត្រាហើយនិងគ្រឹះស្ថាន ឬ អង្គការសាធារណៈទាំងឡាយ ពុំអាចនឹងលាក់បំបាំងនូវការសំងាត់ក្នុងវិជ្ជាជីវៈចំពោះភ្នាក់ងារពន្ធនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលបំពេញមុខងារខាងពន្ធអាករនេះហើយដែលមានលិខិតឧទ្ទេសនាម និងលិខិតបញ្ជាបេសកកម្មត្រឹមត្រូវ ។

*មាត្រា៥៦* ._ ក្នុងករណីដែលអ្នកជាប់ពន្ធអាករ ពុំព្រមបង់ប្រាក់ពន្ធអាករ ឬ ប្រាក់ពិន័យអ្នកជាប់ពន្ធអាករអាចតវ៉ាទៅអង្គការពន្ធថ្នាក់លើតាមលំដាប់ថ្នាក់ អោយលុប ឬ បន្ថយប្រាក់ពន្ធអាករ ឬ ប្រាក់ពិន័យដែលតម្រូវអោយបង់នោះ បើមានភស្តុតាងបញ្ជាក់ថា អង្គការពន្ធថ្នាក់នោះកំណត់មិនត្រឹមត្រូវ ។

បើនៅតែមិនយល់ព្រម ត្រូវបញ្ជូនសំណុំរឿងទៅតុលាការដើម្បីជំនុំជំរះ ។

ក្នុងពេលរង់ចាំការដោះស្រាយបណ្តឹងតវ៉ា អ្នកជាប់ពន្ធអាករត្រូវបង់ប្រាក់ពន្ធអាករ និង ប្រាក់ពិន័យអោយគ្រប់តាមចំនួន និងតាមពេលវេលាកំណត់ ។

*មាត្រា៥៧* ._ ការប្រកាសមិនគ្រប់គ្រាន់ ការប្រកាសពុំត្រង់ ជាទូទៅគឺបទល្មើសទាំងពួងលើបទបញ្ញត្តិនៃច្បាប់នេះត្រូវរងការពិន័យជាប្រាក់ពី ១០.០០០៛ ដល់ ៥០.០០០៛ ហើយបើមានការបន្លំពន្ធអាករ ត្រូវរងការពិន័យបន្ថែមស្មើនឹង២ដងនៃប្រាក់ពន្ធអាករដែលបន្លំនោះ ។

ក្នុងរយៈពេល២ឆ្នាំ បើពុំរាងចាលនៅប្រព្រឹត្តល្មើសទៀតនោះ ចំនួនប្រាក់ពិន័យខាងលើត្រូវឡើងពី ២០.០០០៛ ដល់ ១០០.០០០ ៛ ឯប្រាក់ពិន័យពីការបន្លំពន្ធអាករត្រូវស្មើ ៣ ដងនៃប្រាក់ពន្ធអាករដែលបន្លំ ។

*មាត្រា៥៨* ._ ត្រូវរងការកំណត់ពន្ធអាករតាមផ្លូវការ ចំពោះអ្នកជាប់ពន្ធអាករដែល. :

១_ ពុំបានប្រកាសជូនអង្គការពន្ធ តាមពេលវេលាដែលកំណត់ក្នុងច្បាប់នេះ

២_ ពុំព្រមប្តឹង ឬ ពុំព្រមជូនភស្តុតាងផ្សេង ៗ តាមការស្នើសុំរបស់អង្គការពន្ធក្នុងរយៈពេល ៣០ ថ្ងៃ

៣_ ពុំព្រមបង្ហាញបញ្ជីគណនេយ្យជូនអង្គការពន្ធ

*មាត្រា៥៩* ._ ចំនួនប្រាក់ពន្ធអាករត្រូវបន្ថែម ២៥ ភាគរយ ចំពោះអ្នកជាប់ពន្ធអាករដែលត្រូវគិតពន្ធអាករតាមផ្លូវការ ។ ចំនួនបន្ថែមនេះត្រូវឡើងដល់ ៥០ ភាគរយក្នុងករណីពុំរាងចាលជាលើកដំបូង ដល់ ១០០ ភាគរយក្នុងករណីពុំរាងចាលលើកទី ២ និងឡើងដល់ ២០០ ភាគរយក្នុងករណីល្មើសបន្តទៀត ។

*មាត្រា៦០* ._ ការយឺតយ៉ាវ មិនបានបង់ប្រាក់ពន្ធអាករតាមពេលកំណត់ត្រូវរងការពិន័យជាប្រាក់ស្មើនឹង ៥ ភាគរយក្នុង ១ ខែលើចំនួនប្រាក់ពន្ធអាករដែលត្រូវបង់ ចំពោះអំពើល្មើសជាលើកទី ១ ។

ក្នុងរយៈពេលពីរឆ្នាំ បើពុំរាងចាលនៅប្រព្រឹត្តល្មើសទៀតនោះ អត្រាប្រាក់ពិន័យនេះត្រូវឡើងដល់ ១០ ភាគរយ ចំពោះអំពើល្មើសជាលើកទី ២ និងត្រូវឡើងដល់ ១៥ ភាគរយ ចំពោះល្មើសជាលើកទី ៣ ។

ចំពោះអំពើល្មើសជាបន្តទៀត  អត្រាប្រាក់ពិន័យត្រូវឡើងដល់ ២០ ភាគរយ ។

ការលើកលែងមិនបានបង់ពន្ធអាករនឹងអាចអនុគ្រោះពន្យារពេលបង់ពន្ធអាករ បន្ថយពន្ធអាករ ឬអោយរួចពន្ធអាករ បានតែក្នុងករណីមានមហន្តរាយដល់សកម្មភាពអាជីវកម្ម ឬ ទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធអាករ ឬ អាយុជីវិតរបស់អ្នកជាប់ពន្ធអាករ ។

ការអនុគ្រោះអោយពន្យារពេលបង់ពន្ធអាករ ឬ បន្ថយពន្ធអាករ ឬ អោយរួចពន្ធអាករ  ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា៦១ .. អង្គការពន្ធមានសិទ្ធិ តាមប្រមូលទារប្រាក់ពិន័យដែលអ្នកប្រព្រឹត្តល្មើសបានយល់ព្រមទទួល និង ប្រាក់ពន្ធអាករខ្វះខាតភ្លាត់ពុំបានទារដោយបណ្តាលមកអំពីការប្រព្រឹត្តនៃអ្នកជាប់ពន្ធអាករក្តី បណ្តាលមកពីការភ័ន្តច្រឡំនៃភ្នាក់ងារពន្ធក្តី ក្នុងកំឡុង ៣ ឆ្នាំ គិតចាប់ពីឆ្នាំដែលគិតយកពន្ធអាករ ។

ប៉ុន្តែបើមានការវិវាទឡើងដល់តុលាការហើយរកទៅឃើញថា អ្នកជាប់ពន្ធអាករពុំបានបង់ពន្ធអាករ ឬបង់ពុំគ្រប់គ្រាន់តាមពិតនោះ អង្គការពន្ធអាចទារអោយបង់រហូតដល់ពេលងាចំឆ្នាំ ដែលជាឆ្នាំបន្ទាប់ពីឆ្នាំកាត់សេចក្តី ។

មាត្រា៦២ .. ជនណាដែលបានញុះញង់អ្នកជាប់ពន្ធអាករម្នាក់ ឬ ច្រើននាក់អោយបដិសេធ ឬ ពន្យារការបង់ពន្ធអាករតាមការបំពានឈើរួបរាងកាយ តាមការគំរាមកំហែង ឬ តាមការរៀបចំឧបាយកល សំដៅរាំងស្ទះការកំណត់មូលដ្ឋានគិតពន្ធអាករ ឬ ការយកពន្ធអាករ  ត្រូវទទួលទោសជាប់គុកពី ៦ ខែទៅ ៣ ឆ្នាំ ។

មាត្រា៦៣ .. មន្ត្រី និង ភ្នាក់ងារពន្ធដារដែលបន្លំលួច គៃបំបាត់  ប្រាក់ពន្ធអាករ ប្រាក់ពិន័យ ទារសំណូក អ្នកសូក និង អ្នកកណ្តាលក្នុងបទសូក ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

មាត្រា៦៤ .. ក្រឹត្យច្បាប់លេខ ២៣ ក្រច ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីពន្ធអាជីវកម្ម និង បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៦៥ ..  ច្បាប់ត្រូវប្រកាសជាការប្រញាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័ត
នៅថ្ងៃ ទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ នាសម័យប្រជុំ រដ្ឋសភា លើកទី ១
នីតិកាលទី ១ ។

ភ្នំពេញ , ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

ប្រធានរដ្ឋសភាស្តីទី

ជា ស៊ីម